雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团

ប្រទេសចិន-ខេត្តយូនណាន

ទស្សនាវដ្ដី ប្រចាំថ្ងៃ

YUNNANEXPRESS
english.yunnan.cn

ឆ្នាំទី 24 លេខ 6993 ថ្ងៃសុក្រ ទី 01 ខែមេសា ឆ្នាំ 2016

កិច្ចសហប្រតិបត្តិការអនុតំបន់ទន្លេមេគង្គបណ្តាល ឱ្យមានតម្រូវការកាន់តែខ្លាំងចំពោះអ្នកបកប្រែភាសា

យាន់ ស្យៅលាន
ប៉ៃ ជាងលី

ព័ត៌មានថ្ងៃទី២២ ខែមីនា នៃទីភ្នាក់ងារស៊ីនហួៈ ពេលដែលបានដឹងថា កិច្ចប្រជុំអ្នកដឹកនាំនៃមេគង្គ- ឡានឆាង លើកទី១ជិតនឹងប្រារព្ធលោកយាន ម៉ាងយ៉ាំង និស្សិតអនុបណ្ឌិតភាសាខ្មែរម្នាក់ដែលកំពុងចូលរៀននៅសកលវិទ្យាល័យជនជាតិយូនណានបានសប្បាយរីករាយណាស់ ពីព្រោះមុខវិជ្ជារបស់គាត់កំពុងអភិវឌ្ឍន៍យ៉ាងឆាប់រហ័សដោយសារកិច្ចសហប្រតិបត្តិការទន្លេមេគង្គ- ឡាន ឆាង។

និស្សិតដែលកំពុងតែសិក្សា បណ្តាភាសានៅតំបន់អាស៊ីអគ្នេយ៍នៅ សកលវិទ្យាល័យជាតិយូណាន (រូបថត ដោយYang Zheng)

នៅពេលនៅមិនទាន់បញ្ចប់ការសិក្សា និស្សិតរួមថ្នាក់របស់លោកយាន ម៉ាងយ៉ាំង ក៏ត្រូវនិយោជកនានាកក់ទុកជាមុនអស់ហើយ។ គាត់បានក្លាយជាលោកគ្រូបង្រៀនភាសាខ្មែរម្នាក់របស់សកលវិទ្យាល័យគរុកោសល្យយូនណានដោយមានតែវិញ្ញាបនបត្រថ្នាក់បរិញ្ញាបត្រ តាមធម្មតាមានតែនិស្សិតដែលមានវិញ្ញាបនបត្របណ្ឌិតឬវិញ្ញាបនបត្រអនុបណ្ឌិត ទើបតែមានឱកាសធ្វើជាលោកគ្រូនៅក្នុងសកលវិទ្យាល័យ ។ ប៉ុន្តែដោយគិតដល់តម្រូវការរបស់កិច្ចសហប្រតិបត្តិការមេគង្គ- ឡាន ឆាង ចំពោះបុគ្គលិកថ្នាក់ខ្ពស់ លោកយាន ម៉ាងយ៉ាំង សម្រេចចិត្តថាទៅបន្តការសិក្សានៅសកលវិទ្យាល័យជនជាតិយូនណានដើម្បីសិក្សាយកសញ្ញាបត្រអនុបណ្ឌិត ។

ចាប់តាំងពីទសវត្សរ៍នៃឆ្នាំ១៩៩០មក យន្តការកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ទន្លេមេគង្គ បានកាន់តែមានភាពចម្រុះ សព្វថ្ងៃនេះបានមានយន្តការសហការជាច្រើន ដូចជាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ទន្លេ មេគង្គ- ឡាន ឆាងកិច្ចសហប្រតិបត្តិការនៃការអភិវឌ្ឍអាស៊ានតំបន់ទន្លេមេគង្គ និងគណៈកម្មាធិការទន្លេមេគង្គជាដើម។ ថ្ងៃទី២៣ ខែមីនា កិច្ចប្រជុំអ្នកដឹកនាំ នៃកិច្ចសហប្រតិបត្តិការទន្លេមេគង្គ- ឡានឆាងត្រូវបានប្រារព្ធធ្វើឡើងជាលើកដំបូងនៅទីក្រុងសានយ៉ា ខេត្តហៃណាន។ ប្រទេសទាំង៦បានប្តូរយោបល់គ្នាចំពោះការជំរុញការកសាងនៃ យន្តការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ទន្លេមេគង្គ- ឡាន ឆាងការពង្រឹងកិច្ចសហប្រតិបត្តិការទាំងអស់ជុំគ្នារវាងប្រទេសមហាអនុតំបន់ទន្លេមេគង្គការជំរុញសមាហរណកម្មក្នុងតំបន់និងបញ្ហាផ្សេងទៀត ។

លោកគ្រូលីវ ស្យេវយ៉ុង ដែលបានធ្វើការបង្រៀនរយៈពេល៣៧ឆ្នាំ ហើយនៅក្នុងសកលវិទ្យាល័យជនជាតិយូនណាន បានយល់ឃើញថា តម្រូវការចំពោះធនធានមនុស្សខាងបកប្រែភាសាអាស៊ីអាគ្នេយ៍នឹងកាន់តែច្រើនឡើង ស្របតាមភាពកាន់តែជ្រៅជ្រះនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ទន្លេមេគង្គ- ឡានឆាង។ "កិច្ចសហប្រតិបត្តិការខាងសេដ្ឋកិច្ច វប្បធម៌ ពាណិជ្ជកម្ម និងទេសចរណ៍ជាដើមត្រូវការអ្នកបកប្រែភាសាអាស៊ីអាគ្នេយ៍ខ្លាំងណាស់ ហើយធនធានមនុស្សទាំងនេះនឹងជំរុញការផ្លាស់ប្តូរនិងភាពរុងរឿងក្នុងតំបន់នេះវិញ"។

ខេត្តយូនណានគឺជាខេត្តមួយដែលបានជាប់ទល់នឹងប្រទេសទាំងបីភូមា វៀតណាម និងឡាវ ។ នៅឆ្នាំ២០១៣ ខេត្តយូនណានបានចាប់ផ្តើមសិក្សាអំពីការបង្រៀន និងការបណ្តុះបណ្តាលចំពោះនិស្សិតដែលរៀនភាសាអាស៊ីអគ្នេយ៍ ដើម្បីជំរុញកិច្ចការបណ្តុះបណ្តាលធនធានមនុស្សខាងបកប្រែ។ តាមដំណឹងថា មកដល់ចុងឆ្នាំ២០១៤ ខេត្តយូនណានបានបង្កើតឡើងនូវមូលដ្ឋាន បុគ្គលិកបកប្រែអន្តរជាតិចំនួន១១ សព្វថ្ងៃនេះ និស្សិតដែលកំពុងរៀនភាសាអាស៊ីអគ្នេយ៍ និងអាស៊ីខាងត្បូងមានដល់ទៅប្រមាណ៥.៥០០នាក់ហើយ។ ឥឡូវនេះ មុខជំនាញខាងភាសាអាស៊ីអគ្នេយ៍ និងអាស៊ីខាងត្បូងនៃខេត្តយូនណានបានមានដល់ជាង១០ភាសាដូចជា ភាសាខ្មែរ ភាសាថៃ ភាសាវៀតណាម ភាសាឡាវ ភាសាភូមា ភាសាម៉ាឡេស៊ី ភាសាឥណ្ឌា និងភាសាឥណ្ឌូណេស៊ីជាដើម ។ រៀងរាល់ឆ្នាំមាននិស្សិតរៀនភាសាអាស៊ីអគ្នេយ៍ និងអាស៊ីខាងត្បូងជាច្រើនចូលក្នុងការងារ ហើយទទួលស្វាគមន៍ខ្លាំងណាស់ពីសង្គម ៕

ការសិក្សារបស់ប្រទេសអង់គ្លេសបានបង្ហាញ ពីតម្លៃខាងសុខភាពនៃតែភូអ៊ីរខេត្តយូនណាន

បច្ចុប្បន្ននេះទស្សនាវដ្តីប្រទេសអង់គ្លេស "BritishJournal of Nutrition" បានបង្ហាញថា បើធៀប នឹងតែបៃតង តែភូអ៊ីរដែលដុះឡើងនៅខេត្តយូនណានបានថែរក្សានូវធាតុ ជីវជាតិកាន់តែច្រើនទៀត។ តែភូអ៊ីរមិនគ្រាន់តែមានប្រសិទ្ធភាពក្នុងការ បន្ថយគ្រោះថ្នាក់នៃជំងឺមហារីក និងជំងឺរលាកសន្លាក់ឆ្អឹងរ៉ាំរ៉ៃប៉ុណ្ណោះទេតែវានៅមានប្រសិទ្ធភាពក្នុងការប្រឆាំងនឹងស្នាមជ្រួញផងដែរ។

អ្នកស្រាវជ្រាវនៃសកលវិទ្យាល័យ Kingston ប្រទេសអង់គ្លេស បានសហការជាមួយនឹងក្រុមហ៊ុនគ្រឿងសម្អាង NYR ប្រទេសអង់គ្លេសដូចគ្នា បានធ្វើពិសោធន៍ចំពោះរុក្ខជាតិចំនួន២១ ដើម្បីសិក្សាអំពីតម្លៃខាងសុខភាពរបស់រុក្ខជាតិទាំងនេះ ។ ពួកគេបានរកឃើញថា រុក្ខជាតិទាំងនេះសុទ្ធសឹងមានប្រយោជន៍ចំពោះសុខភាពមនុស្ស ប៉ុន្តែតែភូអ៊ីរមានប្រយោជន៍ច្រើនជាងគេក្នុងចំណោមរុក្ខជាតិទាំងនេះ។ លោក Declan Norton សាស្ត្រាចារ្យនៃសកលវិទ្យាល័យ Kingston បានថ្លែងថា ការសិក្សានេះបានបង្ហាញថា តែភូអ៊ីរមានប្រសិទ្ធភាពប្រឆាំងនឹងភាពចាស់ វាថែមទាំងមានសារធាតុប្រឆាំងអុកស៊ីតកម្មជាច្រើន ចំណែកសារធាតុប្រឆាំងអុកស៊ីតកម្មនេះ វាមានប្រសិទ្ធភាពប្រឆាំងនឹងជំងឺបេះដូងនិងមហារីក។

លោក Norton បានពន្យល់ ថា "ឆ្លងកាត់ការធ្វើពិសោធន៍ យើងបានរកឃើញប្រូតេអ៊ីនដែលអាចការពារស្បែកមនុស្ស ជាពិសេសប្រូតេអ៊ីន Elastin និងប្រូតេអ៊ីនcollagen ។ ប្រូតេអ៊ីន Elastin មានប្រយោជន៍ណាស់ចំពោះសួតសរសៃឈាមសរសៃចង និងស្បែកនៃមនុស្ស ។ ចំណែកប្រូតេអ៊ីន collagen វិញ វាមានប្រយោជន៍ណាស់ចំពោះស្បែកនៃមនុស្ស"។

តាមធម្មតាគេចែកតែជាប្រភេទធំចំនួន៦គឺ តែបៃតងតែក្រហមតែលឿងតែសតែខៀវនិងតែខ្មៅ។ តែភូអ៊ីរគឺជាប្រភេទតែខ្មៅមួយ ប៉ុន្តែវាក៏មានភាពខុសគ្នានឹងតែខ្មៅផ្សេងៗ ។ នៅទូទាំងពិភពលោកមានតែតំបន់តិចតិចសមស្របនឹងការដាំដុះនៃតែភូអ៊ីរ ការផលិតកម្មនៃតែភូអ៊ីរគឺមានប្រវត្តិសាស្ត្រជាង១០០០ឆ្នាំហើយ ។ ស្លឹកនៃដើមឈើតែបុរាណ គឺវត្ថុធាតុដើមដ៏ល្អជាងគេបំផុតសម្រាប់ផលិតតែភូអ៊ីរ នៅពេលដំបូងគេយកតែស្លឹកតែបែបនេះសម្រាប់ផលិតតែភូអ៊ីរដែរ ។

ប្រសិទ្ធភាពចំពោះសុខភាពមនុស្សនៃតែភូអ៊ីរបានធ្វើឱ្យអ្នកស្រាវជ្រាវមានភាពភ្ញាក់ផ្អើលណាស់ ។ លោក Norton គឺជា អ្នកជំនាញការខាងការរលាកល្បីឈ្មោះម្នាក់នៅប្រទេសអង់គ្លេសគាត់និយាយថា: "យើងគ្រាន់តែធ្វើពិសោធន៍ចំពោះតែភូអ៊ីរបរិមាណតិចតួចដែលតិចជាងបរិមាណក្នុងគ្រឿងភេសជ្ជៈ ។ ផលពិសោធន៍បាន បង្ហាញថាតែភូអ៊ីរបានបន្ថយគ្រោះថ្នាក់នៃការរលាក នៃមនុស្ស រីឯការរលាកគឺ ជាលក្ខណៈសំខាន់មួយនៃជំងឺមួយចំនួនដូចជាជំងឺមហារីក ជំងឺរលាកសន្លាក់ឆ្អឹង រ៉ាំរ៉ៃ និងការកើតមានស្នាមជ្រួញឡើងជាដើម"។

មនុស្សពីរជំនាន់ដែលបានការពារសត្វកុក

ដោយៈហ៊ូ ឆាវ

ឃុំដាសានបាវទីក្រុងចាវថុង ខេត្តយូណាន គឺជាទីជម្រកសំខាន់មួយសម្រាប់សត្វកុកកខ្មៅដែលជាសត្វស្ថិតនៅក្នុងការការពារមួយប្រភេទនៅប្រទេសចិន ។ ផ្ទះលោកស្រីដុង យាង-ឡាន និងកូនប្រសាស្រីរបស់គាត់ លោកស្រីឆឺន ក្វាំងហុយ គឺស្ថិតនៅក្បែរតំបន់ដីសើមដាហៃជីដែលជាទីអាស្រ័យនៅពេលយប់នៃសត្វកុកកខ្មៅ គេពីរនាក់ជាមនុស្សជំនាន់ទីពីរដែលបានការពារសត្វកុកកខ្មៅជាមួយគ្នាជាង២០ឆ្នាំហើយ គឺដូចជាញាតិសាលោហិតនៃសត្វកុកកខ្មៅ ។

ជាង១០ឆ្នាំមុន សមាគមការពារសត្វកុកកខ្មៅនៃទីក្រុងចាវថុងបានជ្រើសរើសអ្នកការពារសត្វកុកកខ្មៅនៅឃុំដាសានបាវ លោកស្រីដុង យាងឡានបានក្លាយជាអ្នកការពារសត្វកុកកខ្មៅជំនាន់ទីមួយនៅឆ្នាំនោះ ។ ក្រោយពីលោកស្រីឆឺន ក្វាំងហុយបានចូលផ្ទះនេះ គាត់ក៏ចាប់ផ្តើមទទួលភារកិច្ចនេះលើស្មាខ្លួន ។ ពេលដំបូងបើចង់ដើរជិតនឹងសត្វកុកកខ្មៅគឺពិបាកណាស់ ប៉ុន្តែឆ្លងកាត់ការរៀនតាមម្តាយក្មេកគាត់ លោកស្រីឆឺនក្វាំងហុយបានរកឃើញវិធីមួយដែលទាក់ទងនឹងសត្វកុកកខ្មៅ ហើយបានច្នៃប្រឌិតវិធីទាក់ទងមួយដែលធ្វើតាមការផ្លុំកញ្ចែ ។ សព្វថ្ងៃនេះឱ្យតែឮដល់សំឡេងផ្លុំកញ្ចែរបស់គាត់សត្វកុកកខ្មៅក៏ប្រមូលមករង់ចាំការផ្តល់អាហារពីលោកស្រី ។

លោកស្រីដុង យាងឡាននិងលោកស្រីឆឺន ក្វាំងហុយបានការពារសត្វកុកកខ្មៅជាង២០ឆ្នាំហើយ ផ្ទះរបស់គេក៏ក្លាយជាសណ្ឋាគារមួយដែលឈ្មោះ "សណ្ឋាគារកុកនៅ" ។ ដោយសារមានចម្ងាយជិតជាងគេនឹងតំបន់ដីសើម ហើយងាយស្រួលនឹងសង្កេតសត្វកុកមានអ្នកទេសចរជាច្រើនចូលចិត្តជ្រើសរើសសណ្ឋាគាររបស់ពួកគេជាងគេ ។

ឆ្លងតាមការការពារជាច្រើនឆ្នាំមក ចំនួននៃសត្វកុកកខ្មៅដែលមកឆ្លងកាត់រដូវរងាជារៀងរាល់ឆ្នាំបានឡើងដល់ចំនួនប្រហែល១.២០០ពីចំនួន៣០០នាពេលដែលតំបន់ការពារសត្វកុកកខ្មៅទើបតែត្រូវបង្កើតឡើងនោះ ៕

ឃុំដាសានបាវទីក្រុងចាវថុង ខេត្តយូណាន គឺជាទីជម្រកដ៏សំខាន់មួយ សម្រាប់សត្វកុកកខ្មៅ (រូបថតដោយHu Chao)

យូណានភាពយន្តគ្រុបបានវិនិយោគលើវិស័យភាពយន្តនៅហូលីវូដ

លោកចាំង លួន ប្រធាននៃ យូណានភាពយន្តគ្រុប(រូបកណ្តាល) និងលោកហឺ ចច ឯកអគ្គរដ្ឋទូតប្រទេសឈីលីប្រចាំប្រទេសចិន (រូបស្តាំ) កំពុង ថតរូប (រូបថតដោយលោក Du Jing)

ដោយៈដូ ជីង

ថ្ងៃទី១០ ខែមីនា ភាពយន្តហូលីវូដ"LOS33"ដែល យូណានភាព-យន្តគ្រុបបានចូលរួមវិនិយោគនោះបានចូលរួមមហោស្រពភាពយន្តនៅទីក្រុងប៉េកាំង ។ លោកហឺ ចច ឯកអគ្គ-រដ្ឋទូតប្រទេសឈីលីប្រចាំប្រទេសចិន និងភរិយា និងបេសកជននៃប្រទេសជាច្រើនបានចូលរួមការប្រជុំមើលភាពយន្តនេះ ។ មនុស្សគ្រប់គ្នាបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ខ្លាំងណាស់ចំពោះភាពយន្តនេះ ដែលជាភាពយន្តនិយាយអំពីគ្រោះមហន្តរាយធំមួយ ហើយជារឿងពិតមួយដកចេញពីប្រទេសឈីលី ។

ភាពយន្ត"LOS33"គឺរៀបរាប់អំពីរឿងមួយ ដែលកើតឡើងនៅឆ្នាំ២០១០ គឺមានកម្មកររ៉ែប្រទេសឈីលី៣៣នាក់បានជួបគ្រោះមហន្តរាយអណ្តូងរ៉ែធ្លូន់ធ្ងរខ្លាំង ហើយត្រូវជាប់នៅកន្លែង៧០០ម៉ែត្រក្រោមដី ប៉ុន្តែត្រូវគេជួយសង្គ្រោះក្រោយ៦៩ថ្ងៃនៅទីបំផុតដែលគ្មានកម្មកររ៉ែណាស្លាប់ទេ ។ ភាពយន្តនេះគឺជាភាពយន្តហូលីវូដទីមួយក្នុងឆ្នាំ២០១៦ដែលត្រូវនាំចូលក្នុងប្រទេសចិន ហើយត្រូវបញ្ចាំងយ៉ាងទូលំទូលាយនៅរោងភាពយន្តប្រទេសចិន ។

នៅមហោស្រពភាពយន្តនេះ លោកចាំង លួន ប្រធាននៃយូណានភាពយន្តគ្រុប បានណែនាំថា ក្រោយពីការបញ្ចាំងនៅប្រទេសចិនភាពយន្ត"LOS33"ត្រូវគេសរសើរណាស់ ។ ឆ្លងកាត់ភាពយន្តនេះ យើងបានមើលឃើញដល់ស្មារតីនៃប្រជាជន និងប្រទេសឈីលី។ ហើយលោកឯកអគ្គរដ្ឋទូតហឺចចបានថ្លែងថា "ចំណុចដ៏សំខាន់មួយគឺថា ប្រទេសចិននិងប្រទេសឈីលី គឺជាប្រទេសពីរដែលឆ្ងាយពីគ្នា ហើយ មានប្រវត្តិសាស្ត្រនិងវប្បធម៌ខុសគ្នាណាស់ តាមពិតពិបាកនឹងមានទំនាក់ ទំនងនឹងគ្នាណាស់ ប៉ុន្តែភាពយន្តនេះបានធ្វើឱ្យប្រទេសយើងទាំងពីរទាក់ទងជាមួយគ្នា។ វាបានឆ្លងកាត់មហាសមុទ្រ ដ៏ធំមួយមកដល់ប្រទេសចិនហើយគឺជារឿងដែលមានផលប្រយោជន៍មួយទោះបីវាជាភាពយន្តគ្រោះមហន្តរាយមួយប៉ុន្តែសំខាន់នោះគឺវាមានការបញ្ចប់ល្អ"៕